មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការ សេដាក)
ផ្ទះលេខ ៣៩ ផ្លូវ ៥២៨ សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ១១១៨ ទូរស័ព្ទ: ៨៥៥_២៣_៨៨០ ៩១៦ ទូរសារ: ៨៥៥_២៣_៨៨៥ ១៤៦

# សំណើរជាយុទ្ធសាស្ត្រ ក្នុងការពង្រឹងអំណាចកសិករ ជាអ្នកធ្វើស្រែ

***សេដាក ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៩***

នៅក្នុងឱកាសទិវា **ឆ្នាំនៃសកម្មភាពសម្រាប់ដំណាំស្រូវ ២០០៩-២០១០** នេះ ដែលជាសកម្មភាពផ្តោតលើការថែរក្សា និងការពារពូជស្រូវរបស់កសិករ មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (**សេដាក**) សូមផ្តល់សំណើរជាយុទ្ធសាស្ត្រមួយចំនួនក្នុងការពង្រឹងអំណាចកសិករ ជាអ្នកធ្វើស្រែ ដូចខាងក្រោម:

១- ធ្វើការអប់រំ និងបណ្តុះបណ្តាលដល់កសិករអោយចេះឱ្យតំលៃពូជស្រូវក្នុងស្រុក ដោយធ្វើការថែរក្សា និងជ្រើសរើសពូជស្រូវឱ្យបានល្អ ដើម្បីជៀសវាងពីការអាស្រ័យលើការប្រើប្រាស់ពូជស្រូវខាងក្រៅ (ពូជស្រូវបង្កាត់ និងពូជស្រូវដែលកែច្នៃហ្សែន G.E) ដែលទាមទារនូវការ ប្រើប្រាស់ធនធានខាងក្រៅខ្ពស់។

២- ជំរុញឱ្យកសិករប្តូរការធ្វើស្រែតាមទំលាប់ មកធ្វើតាមវិធីសាស្ត្រសាមញ្ញរបស់ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ (ប.វ.ស) ដែលមានភាពសមស្របសម្រាប់កសិករ និងផ្តល់ផលច្រើនជាងការធ្វើតាមទំលាប់។

៣- យកចិត្តទុកដាក់ និងគិតគូដល់ ការកសាងដីស្រទាប់លើ (ដីស្រែ) តាមរយៈការប្រើប្រាស់នូវជីធម្មជាតិ (ជីកំប៉ុស្តិ៍) ការដាំ និងប្រើប្រាស់ជីស្រស់បៃតង ព្រោះថា ដីស្រទាប់លើគឺជាអាយុជីវិតរបស់ស្រូវ និងកសិករ។

៤- រៀបចំចងក្រងជាសមាគមន៏ ឬសហគមន៏ផលិតស្រូវ និងបង្កើតឱ្យមានឃ្លាំងស្តុកស្រូវ និងម៉ាស៊ីនកិនស្រូវតាមសហគមន៏សហគមន៏ ដែលជាប្រយោជន៏យ៉ាងច្រើនដល់កសិករដូចជា:

- បង្កើនសមត្ថភាព ក្នុងការចរចារតម្លៃ ដើម្បីទទួលបានតម្លៃសមរម្យ
- ផ្តល់ភាពងាយស្រួលដល់អ្នកជំនួញក្នុងការប្រមូលទិញស្រូវ
- ចូលរួមធានានូវសន្តិសុខស្បៀងក្នុងសហគមន៏
- បង្កើតការងារដល់អ្នកមូលដ្ឋាន
- មានវត្ថុធាតុដើម ដូចជា អង្កាម និងកន្ទក់សម្រាប់សហគមន៏

សរុបមក ការអនុវត្តន៏នូវសំណើរជាយុទ្ធសាស្ត្រខាងលើ កសិករនឹងទទួលបាននូវអត្ថប្រយោជន៏ជាច្រើនដូចខាងក្រោម:

- បង្កើនភាពអាស្រ័យលើខ្លួនឯងរបស់កសិករ និងសន្តិសុខស្បៀងនៅតាមសហគមន៏
- ទិន្នផលខ្ពស់ និងមានគុណភាពខ្ពស់អាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ
- បន្សាំបានទៅនឹងការប្រែប្រួលអាកាសធាតុនិងកាត់បន្ថយនូវការបំភាយឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស

Centre d´Etude et de Développement Agricole Cambodgien (CEDAC)
No 39 St. 528, S/K Boeung Kak I, Khan Toul Kork, Phnom Penh - Cambodia
P.O.BOX : 1118, Tel.: 855-23-880 916, Fax: 855-23 885 146, E-mail: cedac@camnet.com.kh